រោគមហារីកកស្បូន

អាចហៅថាមហារីកនៃកស្បូន

អ្វីទៅដែលស្ត្រីត្រូវតែដឹង

- មានជំងឺអេចអាយវី (អេចអាយវីគឺជាវីរុស ដែលបង្កើតជំងឺសីដាហៅអេដ្ស)។
- *មានជំងឺស្វាយប្រម៉ែះនៅលើភេទឬក៏ ជំងឺក្លាមីឌីយ៉ា (ជំងឺទាំងពីរនេះអាចឆ្លង ដោយសារមួមដំណេក មានឈ្មោះថាជំងឺផ្លូវភេទ ឬក៏អេស៍ធីឌីស៍)។*
- បានប្រើថ្នាំសំរាប់ការពារកុំឲ្យមានកូនជាយូរមកហើយ។
- បរិភោគម្ហូបដែលមានជាតិបន្លែ និងផ្លែឈើតិចពេក។
- ឡើងទំងន់ធំធាត់ខ្លាំង។
- មានម្តាយឬក៏បងប្អូនស្រី ដែលធ្លាប់មានជំងឺមហារីកកស្បូន។
- មិនបានទៅពិនិត្យស្បូនឲ្យបានទៀងទាត់៕

តើខ្ញុំអាចធ្វើដូចម្តេចទៅ ដើម្បីជួយរកឲ្យឃើញរោគមហារីកកស្បូន ឲ្យបានទាន់ពេល ?

- ស្ត្រីដែលមានការរួមដំណេក ឬក៏ស្ត្រីដែលមានអាយុលើសពី១៨ឆ្នាំ ត្រូវតែទៅពិនិត្យ ស្បូន (ធ្វើជាប់តេស៍)ជារៀងរាល់ឆ្នាំ។
- ស្ត្រីដែលបានរួមដំណេក ត្រូវតែទៅពិនិត្យស្បូន (ធ្វើជាប់តេស៍) ឲ្យបានរៀងរាល់ឆ្នាំក្នុងកំឡុង៣ឆ្នាំ បន្ទាប់ពីបានរួមដំណេកជាលើកទីមួយ ឬក៏បន្ទាប់ពីមានអាយុ២១ឆ្នាំ។ វេជ្ជបណ្ឌិតរបស់អ្នក អាចឲ្យយោបល់ពីការព្យាបាល ក្នុងការពិនិត្យស្បូននេះ បើសិនជាអ្នកមានអាយុលើសពី៣០ឆ្នាំ ហើយមិនមានបញ្ហាសុខភាពផ្សេងៗ។
- ការពិនិត្យស្បូន (ធ្វើជាប់តេស៍) អាចជួយឲ្យរកឃើញរោគសញ្ញាមហារីកនេះ ឲ្យបានមុន ពេលកំណត់។ ការព្យាបាលអាចបញ្ឈប់ជំងឺមហារីកកស្បូននេះ។ ពេលពិនិត្យស្បូនវេជ្ជបណ្ឌិត នឹងស្ទាបសរីរាង្គរបស់ស្ត្រីភេទ ពិនិត្យមើលទំហំនិងរាងរៅ។ ការពិនិត្យស្បូន អាចជួយឲ្យរកឃើញជំងឺនៅលើសរីរាង្គរបស់ស្ត្រីភេទ ក៏ប៉ុន្តែវាមិន អាច ឲ្យជួយរកឃើញរោគមហារីកកស្បូន ដែលទើបតែនិងកើតថ្មីៗនេះទេ។ ដើម្បីរកឲ្យឃើញការពិនិត្យស្បូន(ធ្វើជាប់តេស៍) ត្រូវតែប្រណិបត្តិ៕

តទំព័រខាងក្រោយ

អ្វីទៅដែលខ្ញុំត្រូវកត់សំគាល់?

រោគមហារីកកស្បូនតែងតែ មិនសូវមានរោគសញ្ញាអ្វីទេ។ ហេតុដូច្នេះការពិនិត្យស្បូនឲ្យបានទៀងទាត់គឺជាការចំបាច់ សំរាប់ស្ត្រីទូទៅ។ រោគសញ្ញា មហារីកបង្ហាញឲ្យឃើញនៅពេលដែលវាឆ្លងរាលដាលទៅកន្លែងដ៏ទៃទៀតនៅក្នុងខ្លួនរួចទៅហើយ។ អ្នកគួរនិយាយប្រាប់វេជ្ជបណ្ឌិតរបស់អ្នកជាបន្ទាន់ពេលណាមានរោគសញ្ញាដូចខាងក្រោមនេះ៖

- ធ្លាក់សដែលមិនមែនជាការធម្មតាពីរន្ធយោនី(ឬទ្វាមាស) (ដែលមានការខុសផ្លែកពីការធ្លាក់រដូវធម្មតារបស់អ្នក)។
- ធ្លាក់ដំណក់ឈាម ឬក៏ធ្លាក់ឈាមតិចៗ ដែលមានការខុសផ្លែកពីការធ្លាក់រដូវធម្មតារបស់អ្នក។
- ធ្លាក់ឈាម ឬក៏ជីចុកចាប់នៅពេលរួមដំណេក។

រោគសញ្ញាទាំងនេះមិនមែនមានសេចក្តីថាអ្នកមានជំងឺមហារីកនោះទេ។ ជំងឺនេះអាចកើត ឡើងដោយសារឿងផ្សេងៗទៀតក៏ប៉ុន្តែអ្នកត្រូវតែទៅពិនិត្យវេជ្ជបណ្ឌិតរបស់អ្នក ទើបអាចដឹងបាន។

តើអ្វីទៀតដែលធ្វើឲ្យជំងឺនេះកាន់តែមានគ្រោះថ្នាក់ថែម?

ជំងឺមហារីកកស្បូនមានលក្ខណៈដូចតទៅ ៖

- ការរួមដំណេកចាប់ផ្តើមតាំងពីអាយុវ័យក្មេង។
- ការរួមដំណេកជាមួយដៃគូរច្រើន។
- ការរួមដំណេកជាមួយបុគ្គលដែលធ្លាប់រួមដំណេកជាមួយអ្នកដទៃជាច្រើនរូប។
- ធ្លាប់មានដំបៅជាមួយវីរុសដែលអាចឲ្យមានឫសនៅលើភាទ (វីរុសមានឈ្មោះថា ហ្សូមិនប៉ាបពីម៉ាឬក៏អេជភីវី)។ក៏ប៉ុន្តែ ស្ត្រី ទាំង នោះដែលបានឆ្លងរោគអេជភីវី ឬក៏រោគឫសនៅលើភេទនេះ ក៏មិនមានន័យថាជំងឺទាំងនោះបណ្តាយ ឲ្យកើតជំងឺមហារីកកស្បូននោះទេ។
- ពិសារបារី។



ព្យាបាលរោគមហារីកកស្បូនតាមវិធីណាខ្លះ?

វេជ្ជបណ្ឌិតអាចព្យាបាលរោគមហារីកកស្បូនតាមលក្ខណៈច្រើនយ៉ាង។ បើសិន ការពិនិត្យស្បូន(ធ្វើជាប់តេស៍) រកឃើញកោសិកានៅក្នុងស្បូន ដែលមិនមែនជាធម្មតា វេជ្ជបណ្ឌិតអាចយកចេញ ឬក៏កំទិចវាចេញមុន នឹងវាក្លាយទៅជាមហារីក។ បើរកឃើញរោគ មហារីកស្បូនហើយ គេមានវិធីច្រើនដើម្បីព្យាបាលជំងឺនេះ។ ការព្យាបាលទៅ តាមតើមហារីក នេះ បានឆ្លងរាលដាលដល់ណានៅក្នុងខ្លួន។

ការព្យាបាលអាចប្រើតាមរបៀបតែមួយ ឬក៏របៀបរួមគ្នាដូចជា៖

- ការវះកាត់
- ការព្យាបាលតាមកម្មវិធី
- ការព្យាបាលតាមថ្នាំគីម៉ូ



ស្ត្រីដែលមានការរួមដំណេក ឬក៏ស្ត្រីដែលមានអាយុលើសពី១៨ឆ្នាំ ត្រូវតែទៅពិនិត្យស្បូន (ធ្វើជាប់តេស៍)ជារៀងរាល់ឆ្នាំ។

តើខ្ញុំអាចរស់បានរបៀបណាក្រោយពីមានជំងឺមហារីកកស្បូន នេះ ?

បើរកឃើញរោគមហារីកកស្បូន ហើយព្យាបាលឲ្យបានលឿន វាប្រហែលនិងអាចជាសះ ស្បាយបាន។

ការណាបើមានស្ត្រីភាគច្រើនទៅពិនិត្យស្បូន (ធ្វើជាប់តេស៍) វេជ្ជបណ្ឌិតអាច រកឃើញរោគមហារីកនេះឲ្យបានទាន់ពេល។ ការទៅពិនិត្យស្បូន(ធ្វើជាប់តេស៍) ជារៀង រាល់ឆ្នាំគឺជាការប្រសើរបំផុត ក្នុងការព្យាយាមរកជំងឺនេះឲ្យបានទាន់ពេលវេលា។ មហារីក កស្បូននេះក៏អាចបណ្តាលឲ្យក្លាយទៅជារោគសាហាវបំផុត បើសិនជារកមិនឃើញ។

- ស្ត្រីជិត៩នាក់ ក្នុងចំណោម១០នាក់ (៨៥ភាគរយ)នឹងរស់បាន៥ឆ្នាំឬក៏ច្រើនជាងនេះ

  បើសិនជារកឃើញរោគមហារីកនេះឲ្យបានមុនពេលវារាលដាលទៅក្រៅពីកស្បូន។

និយាយប្រាប់ វេជ្ជបណ្ឌិតបើអ្នកមានរោគសញ្ញាទាំងនេះ។ ពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នកបើសិនជាអ្នកមានសំនួរអ្វីទៀតអំពីសុខភាពរបស់អ្នក ឬក៏ការព្យាបាល របស់អ្នក។
វេជ្ជបណ្ឌិតរបស់អ្នកអាចឲ្យពត៌មានបន្ថែមទៀត ស្តីអំពីរោគមហារីកកស្បូននេះ។

ពត៌មាន: *California Cancer Registry (CDHS/CSS)*

American Cancer Society Facts and Figures 2004.

ពត៌មានទាំងនេះអាចផ្តិតចេញពីក្រសួងរាក់សារសុខភាពស្ត្រីប្រចាំរដ្ឋកាលី www.dhs.ca.gov/director/owh.

Arnold Schwarzenegger, Governor
State of California

S. Kimberly Belshé, Secretary
Health and Human Services Agency

Sandra Shewry, Director
Department of Health Services

Revised 11/04